**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គណៈកម្មការប្រឹក្សាការងារ**

# សេចក្តីថ្លែងការណ៍របស់គណៈកម្មការប្រឹក្សាការងារ

កាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង៣:០០នាទីរសៀល នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គណៈកម្មការប្រឹក្សាការងារបានបើកកិច្ចប្រជុំអាណត្តិទី៨ លើកទី១៧ ដើម្បីបន្តពិនិត្យពិភាក្សាលើរបាយការណ៍លទ្ធផលកិច្ចប្រជុំក្រុមការងារបច្ចេកទេសត្រីភាគី ដើម្បីពិភាក្សាប្រាក់ឈ្នួលអប្បបរមាផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៨ ដែលបានបើកកិច្ចប្រជុំអស់រយៈពេល ៣ថ្ងៃ ស្មើនឹង ៤លើកកន្លងមក។

ក្រោយការពិភាក្សាគ្នា ភាគីទាំងបី បានឯកភាពគ្នាជាឯកច្ឆន្ទគាំទ្រតួលេខ ១៦៥ (មួយរយហុកសិបប្រាំ) ដុល្លារអាមេរិក ជាតួលេខប្រាក់ឈ្នួលអប្បបរមា ក្នុងមួយខែ សម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៨ ។

ដូច្នេះ គណៈកម្មការប្រឹក្សាការងារសូមស្នើតួលេខចំនួន ១៦៥ (មួយរយហុកសិបប្រាំ) ដុល្លារអាមេរិក ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធ្វើការពិនិត្យសម្រេចលើប្រាក់ឈ្នួលអប្បបរមា សម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៨ ដែលត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ តទៅ ស្របទៅតាមបទប្បញ្ញត្តិជាធរមាននៃច្បាប់ស្តីពីការងារ។

*រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៧*

| **ប្រធានគណៈកម្មការប្រឹក្សាការងារ** | **អនុប្រធានគណៈកម្មការប្រឹក្សាការងារ**<br>**ភាគីតំណាងនិយោជក** | **អនុប្រធានគណៈកម្មការប្រឹក្សាការងារ**<br>**ភាគីតំណាងកម្មករនិយោជិត** |
| --- | --- | --- |
| បណ្ឌិត **អ៊ិត សំហេង** | ឧកញ៉ាបណ្ឌិត **ណាង សុធី** | បណ្ឌិត **ជួន មុំថុល** |